# វេរត្រៃចីវរថា:

មយំ ភន្តេ ឥមំ (តិចីវរំ ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ មយំ ភន្តេ ឥមំ (តិចីវរំ ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

តតិយម្បិ មយំ ភន្តេ ឥមំ (តិចីវរំ ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

*បពិត្រព្រះសង្ឃដ៏ចំរើនខ្មើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវ ( ត្រៃចីវរ ) នេះ មកតំកល់ទុកក្នុងទីនេះ សូមវេរប្រគេនចំពោះព្រះសង្ឃ ។*

*បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកនូវ ( ត្រៃចីវរ ) នេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។*

*អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។*

បើសំពត់នោះមានច្រើនត្រៃឬច្រើនផ្ទត់ ត្រូវឱ្យឈ្មោះសំពត់នោះជាបាលីពហុវចនៈ មកដាក់បញ្ចូលវេរ ដូចមានសំណៅជាបែបទុកខាងក្រោមនេះស្រាប់ ។

| | |
|---|---|
| ១- ឥមានិ តិចីវរានិ | *នូវសំពត់ត្រៃចីវរទាំងឡាយនេះ ។* |
| ២- ឥមានិ វស្សិកសាដិកាយោ | *នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ ។* |
| ៣- ឥមានិ និសីទនានិ | *នូវសំពត់សម្រាប់អង្គុយទាំងឡាយនេះ ។* |
| ៤- ឥមានិ បច្ចត្ថរណានិ | *នូវសំពត់កំរាលទាំងឡាយនេះ ។* |

៥- ឥមានិ គណ្ឌុប្បដិច្ឆាទិនិ *នូវសំពត់សម្រាប់គ្របបូសទាំងឡាយនេះ ។*

៦- ឥមានិ មុខបុញ្ឆនចោឡានិ *នូវសំពត់សម្រាប់ជូតមុខទាំងឡាយនេះ ។*

៧- ឥមានិ បរិក្ខារចោឡានិ *នូវសំពត់បរិក្ខារចោឡទាំងឡាយនេះ ។*

៨- ឥមានិ បរិសាវនានិ *នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយនេះ ។*

៩- ឥមានិ វស្សាវាសិកាយោ *នូវសំពត់ចំណាំវស្សាទាំងឡាយនេះ ។*

១០- ឥមានិ អច្ឆេកចីវរានិ *នូវសំពត់អច្ឆេកចីវរទាំងឡាយនេះ ។*

សំពត់ទាំង១០ប្រការនេះ បើត្រូវការនឹងរើសសំពត់ណាមួយឱ្យយកឈ្មោះសំពត់នោះមកដាក់ជាបាលី សម្រាប់សូត្រវេរខាងមុខនោះចុះ ត្រង់កន្លែងដែលបានវង់ក្រចកនោះស្រាប់ ។

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុខ** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១២

